សួស្ដី នៅក្នុងរូបភាពនេះគឺនិយាយអំពីរដូវរងា
ដែលនៅក្នុងប្រទេសកម្ពុជាយើងគឺមានការបែងចែកជាពីររដូវ រដូវប្រាំង និងរដូវវស្សា។
រដូវប្រាំងគឺយើងសំដៅទៅលើរដូវក្ដៅ និងរដូវវស្សាគឺយើងសំដៅទៅលើរដូវ រដូវភ្លៀង
គឺយើងសំដៅទៅលើរដូវភ្លៀង។ ប៉ុន្តែនៅឆ្នាំខ្លះ នៅ នៅ[អំឡុង] នៅអំឡុងខែ ១២ ឬក៏ខែ ១
នៅអំឡុងខែ ១២ ឬក៏ខែ ១ យើង អត់មានពន្លឺថ្ងៃ និងមានខ្យល់បក់ ដូច្នេះវាគឺជារដូវរងាសម្រាប់
សម្រាប់ប្រជាជនខ្មែរ។ ដោយសារតែនៅកម្ពុជាយើងអត់មាន
ដោយសារតែនៅកម្ពុជាយើងអត់មានទឹកកកធ្លាក់ទេ ប៉ុន្តែនៅពេលដែល នៅពេលដែល មាន
នៅពេលដែលមានខ្យល់បក់ខ្លាំង និងអត់មានពន្លឺថ្ងៃ និងអត់មានពន្លឺថ្ងៃ និងពេលខ្លះមានភ្លៀងតិចៗ
នេះគឺជារដូវត្រជាក់សម្រាប់ពួកយើង។ ដែលជាក់ស្តែងនៅក្នុងរូបភាពទី ១ រូបភាពទី ១
យើងឃើញមានបុរសម្នាក់ គាត់កំពុងគេងលក់យ៉ាងស្រួលនៅលើគ្រែក្នុងបន្ទប់គេងរបស់គាត់
ដែលយើងឃើញនៅក្នុងបន្ទប់គេងរបស់គាត់ យើងឃើញមានគ្រែគេងមួយ
ដែលគ្រែគេងរបស់គាត់គឺដាក់នៅជាប់នឹងជញ្ជាំងជិតនឹងមាត់បង្អួចកញ្ចក់របស់គាត់។
ដែលបង្អួចកញ្ចក់របស់គាត់គឺមានវាំងននអមសងខាង ប៉ុន្តែគាត់មិនបានបិទវាំងននទោះទេ
ដោយសារតែគាត់ចង់ឲ្យមានពន្លឺព្រះអាទិត្យចាំងចូលមកខាងក្នុងបន្ទប់របស់គាត់
នៅពេលព្រឹកនៅពេលដែលព្រះអាទិត្យរះ។ និងនៅក្បែរបង្អួចកញ្ចក់នោះយើងឃើញមានរូបថតមួយ
យើងឃើញមានរូបថតមួយ ដែលព្យួរជាប់នឹងជញ្ជាំងក្បែរនឹងមាត់បង្អួចនោះ ប្រហែលជារូបថតគាត់
ឬក៏រូបថត[គ្រួសារ] ប្រហែលជារូបថតគាត់ ឬក៏ជារូបថតគ្រួសាររបស់គាត់
ដែលមានឪពុកម្ដាយនិងគាត់។ ដែលយើងឃើញ និង និងយើងឃើញបុរសម្នាក់នោះ
គាត់មិនទាន់ភ្ញាក់ គាត់មិនទាន់ក្រោកពីគេងទេ គាត់មិនទាន់ក្រោកពីគេងទេ
អញ្ចឹងយើងឃើញគាត់គេងលក់យ៉ាងស្រួល យើងឃើញគាត់គេងលក់ស្រួលនៅលើគ្រែរបស់គាត់
ដោយយើងឃើញគាត់កើយខ្នើយនិងដណ្ដប់ភួយ។ ដោយសារតែយើងក្រឡេកមើលទៅខាងក្រៅ
យើងឃើញមាន យើងឃើញមានខ្យល់បក់ខ្លាំង និងអត់មានព្រះអាទិត្យ ដូច្នេះវាគឺចាប់ផ្ដើម
ដូច្នេះគឺចាប់ផ្ដើមរដូវរងា អញ្ចឹងគាត់ត្រូវដណ្ដប់ភួយបើទោះបីជាគាត់នៅក្នុងផ្ទះ
ឬក៏ក្នុងបន្ទប់គេងរបស់គាត់ក៏ដោយ។ ពីព្រោះប្រសិនបើគាត់មិនបានដណ្ដប់ភួយទេ គាត់អាច
គាត់អាចឈឺ ឬក៏ផ្ដាសាយយ៉ាងងាយស្រួល ដោយសារតែខាងក្រៅគឺមានអាកាសធាតុត្រជាក់។
និងយើងឃើញនៅក្បែរគ្រែរបស់គាត់ ក្បែរក្បាលគ្រែរបស់គាត់យើងឃើញមានតុមួយ
ដែលតុនោះយើងឃើញមានបីថត តុនោះយើងឃើញមានបីថត
នៅលើតុនោះយើងឃើញមានអំពូលភ្លើងបញ្ឈរដាក់នៅតុនោះ
ដែលអំពូលភ្លើងនោះគឺប្រើសម្រាប់បិទ ឬក៏បើក មានន័យថានៅពេលដែលគាត់
មានន័យថាមុនពេលដែលគាត់ចូលគេង គាត់អាចប្រើអំពូលភ្លើងនោះដើម្បីអានសៀវភៅ
ឬក៏មើលទូរទស្សន៍។ ប៉ុន្តែនៅពេលដែលគាត់ចូលគេង គាត់អាចបិទអំពូលភ្លើងនោះ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ដោយគ្រាន់តែឈោងដៃចុចកុងតាក់ អញ្ចឹងអំពូលភ្លើងនោះនឹងរលត់។
និងយើងឃើញនៅក្បែរអំពូលភ្លើងបញ្ឈរនោះ យើងឃើញមាននាឡិការោទ៍មួយ
ដែលនាឡិការោទ៍នោះគឺប្រើសម្រាប់កំណត់ម៉ោង ឬក៏កំណត់ពេលវេលាដែលគាត់ចង់ ដែលគាត់ចង់
ដែលគាត់ចង់ក្រោកពីគេង ដើម្បី ដើម្បីកុំឲ្យយឺតក្នុង ដើម្បីកុំឲ្យយឺតទៅសាលា អញ្ចឹងគាត់ត្រូវ
គាត់ត្រូវកំណត់ម៉ោង គាត់ត្រូវកំណត់ម៉ោង ពីព្រោះនៅពេលដែលគាត់កំណត់ម៉ោងណាមួយ
នាឡិកានោះនឹងរោទ៍បញ្ចេញសំឡេងជាសញ្ញាប្រាប់ដល់គាត់។

និងរូបភាពទី ២ រូបភាពទី ២ ក្រោយពេលដែលគាត់ ក្រោយពេលដែលនាឡិកានោះរោទ៍
នៅពេលព្រឹកព្រលឹម អញ្ចឹងក្រោយពេលដែលនាឡិការោទ៍ គាត់ក៏ គាត់ក៏ភ្ញាក់ដឹងខ្លួន
គាត់ក៏ភ្ញាក់ដឹងខ្លួន។ បន្ទាប់មកគាត់ក៏ក្រោកអង្គុយ គាត់ក៏ក្រោកអង្គុយ ប៉ុន្តែគាត់មិនទាន់
គាត់មិនទាន់ក្រោកចេញពីគ្រែទេ គាត់នៅអង្គុយនៅលើគ្រែនៅឡើយ
ដោយភួយរបស់គាត់ដណ្ដប់នៅលើជើងរបស់គាត់។ អញ្ចឹង[គាត់] គាត់គ្រាន់តែក្រោកអង្គុយ
និងពត់ខ្លួន និងស្ងាប។ អញ្ចឹងយើងឃើញដៃរបស់គាត់ពត់ទៅលើចុះក្រោម
និងដៃម្ខាងទៀតគឺទប់មាត់របស់គាត់ដោយសារតែគាត់ស្ងាប
នៅពេលដែលស្ងាបគឺមាត់របស់យើងហាធំ ដូច្នេះគាត់យកដៃទប់មាត់របស់គាត់
អញ្ចឹងគាត់កំពុងតែស្ងាបនិងពត់ខ្លួន ក្រោយពេលដែល ក្រោយពេលដែលភ្ញាក់
ក្រោយពេលដែលនាឡិការោទ៍ដាស់គាត់ឲ្យក្រោកដើម្បីទៅសាលារៀនឲ្យទាន់ពេល
អញ្ចឹងយើងឃើញ អញ្ចឹងយើងឃើញគាត់ក្រោកអង្គុយដែល ដែលគាត់ខ្នងរបស់គាត់ផ្អែកនឹង
ផ្អែកនឹងខ្នើយ និងពត់ខ្លួនបណ្ដើរស្ងាបបណ្ដើរ។
អញ្ចឹងនាឡិកានោះបានរោទ៍ដាស់គាត់ឲ្យភ្ញាក់ដឹងខ្លួន។

បន្ទាប់មកទៀតរូបភាពទី ៣ រូបភាពទី ៣ ក្រោយពេលដែលគាត់ភ្ញាក់ដឹងខ្លួនហើយ
គាត់ក៏បានចុះពីលើគ្រែដើរតម្រង់ទៅក្នុងបន្ទប់ទឹករបស់គាត់។
យើងឃើញគាត់ស្លៀកពាក់ឯកសណ្ឋានជា ជាខោអាវគេងយប់ មានន័យថាគាត់ស្លៀក
គាត់ស្លៀកពាក់ខោអាវគេងយប់សម្រាប់គេងយប់។
ដោយសារតែខោអាវគេងយប់គឺរៀងធំជាងខ្លួនបន្តិច និង ឬក៏រលុង ដូច្នេះធ្វើឲ្យ
ដូច្នេះនៅពេលដែលគេងគឺគាត់ចូលចិត្តស្លៀកពាក់ខោអាវណារលុង
ស្លៀកពាក់ខោអាវណាដែលរលុង និងមិនចង្អៀត អញ្ចឹងយើងឃើញខោអាវគេងយប់របស់គាត់គឺ
យើងឃើញមានអាវដៃវែង និងមានឡេវមួយជួរនៅខាងមុខ និងស្លៀកខោ និងគាត់ស្លៀកខោជើងវែង
និងគាត់ស្លៀកខោជើងវែងដែលជាខោអាវគេងយប់របស់គាត់។ ជាទូទៅខោអាវធ្វើការ
ខោអាវទៅសាលារៀន ឬក៏ខោអាវ ខោអាវធ្វើការ ឯកសណ្ឋានសិស្សទៅសាលារៀន

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ខោអាវសម្រាប់គេងយប់។ អញ្ចឹងគឺយើងមានខុសគ្នា និងបែងចែកខុសគ្នា អញ្ចឹងយើងឃើញគាត់
គាត់ដើរតម្រង់ចូលមកក្នុងបន្ទប់ទឹកដែលយើងឃើញគាត់មានកាន់កន្សែងពោះគោនៅក្នុងដៃ
កាន់កន្សែងពោះគោនៅក្នុងដៃខាងស្តាំរបស់គាត់ អញ្ចឹងគាត់យកកន្សែងពោះគោនោះសម្រាប់នៅ
សម្រាប់ជូតខ្លួន នៅពេលដែលគាត់ងូតទឹកហើយ
គាត់អាចប្រើកន្សែងពោះគោនោះជូតខ្លួនគាត់ឲ្យស្ងួត ពីព្រោះប្រសិនបើ
ប្រសិនបើគាត់មិនបានជូតខ្លួនឲ្យស្ងួតទេគឺ នៅពេលដែលទឹក នៅពេលដែលទឹកធ្លាក់ ធ្លាក់នៅ[ឥដ្ឋ]
នៅលើឥដ្ឋ អញ្ចឹងអាចធ្វើឲ្យគាត់ដើររអិលដួល អាចធ្វើឲ្យគាត់ដើររអិលដួលបាន។
និងនៅពេលដែលគាត់មិនបានជូតខ្លួនស្ងួត
នៅពេលដែលគាត់ពាក់ខោអាវគេងយប់នោះដើម្បីត្រលប់ទៅបន្ទប់គេងប្តូរខោអាវរបស់គាត់
អញ្ចឹងអាចធ្វើឲ្យខោអាវគេងយប់នោះទទឹក។
និងពេលខ្លះនៅពេលដែលយើងពាក់អាវទទឹកអាចធ្វើឲ្យយើងផ្តាសាយ និងឈឺផងដែរ
ដោយសារតែអាកាសធាតុនៅខាងក្រៅត្រជាក់ផង
អញ្ចឹងយើងឃើញគាត់តម្រង់ដើរចូលមកក្នុងបន្ទប់ទឹក។ យើងឃើញនៅក្នុងបន្ទប់ទឹករបស់គាត់
យើងឃើញមាន យើងឃើញមានដូចជា[ម៉ាស៊ីន] យើងឃើញមានម៉ាស៊ីនទឹកក្តៅ
ម៉ាស៊ីនទឹកក្តៅគឺយើងប្រើសម្រាប់ធ្វើឲ្យទឹកក្តៅ
អញ្ចឹងនៅពេលដែលយើងចង់ងូតទឹកក្តៅយើងគ្រាន់តែចុចកុងតាក់ ឬក៏[...] ឬក៏ ឬក៏
ឬក៏បញ្ជាកុងតាក់នោះ ដើម្បីឲ្យទឹកនោះក្តៅអ៊ុនៗ ឬក៏ក្តៅអ៊ុនៗ ឬក៏ក្តៅល្មម
អញ្ចឹងយើងអាចងូតទឹកផ្កាឈូកនោះបានដោយមិនបាច់ដាំទឹកទេ។ ជាធម្មតា ឬក៏ជា ជាធម្មតា
ឬក៏ជាទូទៅ នៅផ្ទះខ្លះគឺគាត់អត់មានម៉ាស៊ីន គឺគាត់អត់មានម៉ាស៊ីនសម្រាប់ធ្វើឲ្យ
អត់មានម៉ាស៊ីនទឹកក្តៅទេ អត់មានម៉ាស៊ីនធ្វើឲ្យទឹកក្តៅទេ អញ្ចឹងគាត់ត្រូវក្រោកពីព្រលឹម
និងត្រូវបង្កាត់ភ្លើង ឬក៏គាត់ត្រូវបង្កាត់ភ្លើង ឬក៏គាត់ប្រើចង្ក្រាន ចង្ក្រានហ្គាសដើម្បីដាំទឹកឲ្យក្តៅ។
បន្ទាប់មកគាត់យកទឹកដែលដាំនោះយកចាក់ចូលទៅក្នុងធុង និងលាយទឹកត្រជាក់ ដើម្បីឲ្យ
ដើម្បីងូតទឹកក្តៅអ៊ុនៗ ដោយសារតែអាកាសធាតុនៅខាងក្រៅត្រជាក់។
អញ្ចឹងប្រសិនបើគាត់ងូតទឹកត្រជាក់គាត់អាចឈឺ ឬក៏ផ្តាសាយបានយ៉ាងងាយស្រួល
អញ្ចឹងជាក់ស្តែងនៅក្នុងរូបភាពទី ៣ គឺគាត់មានម៉ាស៊ីន ម៉ាស៊ីនទឹកក្តៅ ម៉ាស៊ីនទឹកក្តៅ
អញ្ចឹងយើងឃើញម៉ាស៊ីនទឹកក្តៅនោះគឺ យើងឃើញ យើងឃើញមានទឹកផ្កាឈូក និងមានម៉ាស៊ីន
និងមានកុងតាក់ប្រើសម្រាប់បញ្ជា ឬក៏កុងតាក់ប្រើសម្រាប់ធ្វើឲ្យ
ធ្វើឲ្យទឹកដែលចេញមកខាងក្រៅនោះគឺក្តៅល្មម ល្មមសម្រាប់ងូត និងយើងឃើញមាន
អញ្ចឹងយើងឃើញមានកន្លែង មានកន្លែងផ្លាស់ខោអាវ ឬក៏យើងឃើញវាំងននបាំងនោះ
ប្រហែលជាគាត់ចូលទៅខាងក្នុងនោះដើម្បីផ្លាស់ខោអាវ
ឬក៏ក្នុងវាំងននោះគាត់អាចងូតទឹកនៅក្នុងនោះក៏បានដែរ។ អញ្ចឹងយើង

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

អញ្ចឹងយើងឃើញគាត់ដើរចូលតម្រង់ទៅម៉ាស៊ីនទឹកក្តៅនោះសម្រាប់ ដើម្បីងូតទឹកក្តៅអ៊ុនៗ
ពីព្រោះដោយសារតែនៅខាងក្រៅអាកាសធាតុត្រជាក់។ អញ្ចឹងអ្នកនៅទីក្រុងគឺគាត់ងាយស្រួល
គាត់គ្រាន់តែចូលទៅក្នុងបន្ទប់ទឹក មានម៉ាស៊ីនទឹកក្តៅស្រាប់ធ្វើឲ្យទឹកក្តៅ
និងមានទឹកត្រជាក់ផងដែរ។ ប៉ុន្តែអ្នកដែលរស់នៅតាមជនបទ
ឬក៏គ្រួសារខ្លះគាត់អត់មានលទ្ធភាពទិញម៉ាស៊ីនទឹកក្តៅនោះទេ។ អញ្ចឹងគាត់ត្រូវដាំទឹកនោះឲ្យក្តៅ
និងលាយជាមួយនឹងទឹកត្រជាក់ ដើម្បីឲ្យទឹកត្រជាក់នោះក្តៅល្មម ដូច្នេះគាត់អាចងូតបាន។
និងយើងឃើញ [និង]យើងឃើញនៅខាងក្រោមឥដ្ឋនោះដូចជាមាន
ដូចជាមានក្រណាត់សម្រាប់ជូតជើង អញ្ចឹងមានន័យថានៅពេលដែលគាត់ដើរចូលទៅក្នុងបន្ទប់
ដែលមាន យើងឃើញមានវាំងននបាំងនោះ យើងឃើញមានវាំងននបាំងនោះ
គាត់អាចចូលទៅងូតទឹកនៅខាងក្នុង បន្ទាប់មកគាត់អាចចេញមកខាងក្រៅ និងជូតជើង[ជាមួយ]
និងជូតជើងឲ្យស្ងួតជាមួយនឹងក្រណាត់ជូតជើងដែលគាត់ដាក់នៅក្នុងបន្ទប់ទឹកនោះ។

បន្ទាប់មកទៀតរូបភាពទី ៤ រូបភាពទី ៤ ដើម្បីចង់ឲ្យទឹកនោះចេញមកខាងក្រៅក្តៅល្មម។
ដូច្នេះគាត់ត្រូវចុចកុងតាក់ដោយយើងឃើញកុងតាក់នៅក្នុងម៉ាស៊ីននោះគឺមានពណ៌ក្រហម
អញ្ចឹងគាត់ធ្វើឲ្យទឹកនោះក្តៅល្មមដែលអាចងូតបាន។
ពេលខ្លះប្រសិនបើយើងអត់ចេះប្រើកុងតាក់នោះទេ អញ្ចឹងពេលខ្លះយើងចុចកុងតាក់
យើងចុចកុងតាក់ខុសទឹកនោះក្តៅខ្លាំង អញ្ចឹងនៅពេលដែលងូតនៅលើខ្លួនយើង
អាចធ្វើឲ្យយើងរលាកបាន អញ្ចឹងយើងមាន យើងមានកុងតាក់សម្រាប់ សម្រាប់ ធ្វើឲ្យទឹកត្រជាក់
ឬក៏ទឹកក្តៅអ៊ុនៗ ឬក៏ទឹកក្តៅខ្លាំង ដែលយើងឃើញ យើងឃើញទឹកផ្កាឈូករបស់គាត់
គឺយើងឃើញទឹកផ្កាឈូករបស់គាត់ និងមាន[ម៉ាស៊ីន] ទឹកផ្កាឈូករបស់គាត់មាន មានម៉ាស៊ីន
មានម៉ាស៊ីនធ្វើឲ្យទឹកក្តៅ មានម៉ាស៊ីនធ្វើឲ្យទឹកក្តៅ អញ្ចឹងទឹកផ្កាឈូកនោះ
នៅពេលដែលបើកយើងចង់ នៅពេលដែលបើក
បើសិនបើយើងចង់បើកទឹកត្រជាក់យើងគ្រាន់តែបើក យើងគ្រាន់តែបើកកុងតាក់ទៅ
យើងគ្រាន់តែបើក ឬក៏មួលវាទៅ អញ្ចឹងទឹកនឹងចេញមកខាងក្រៅត្រជាក់
ប្រសិនបើយើងចង់បានទឹកក្តៅអ៊ុនៗល្មម យើងគ្រាន់តែចុចកុងតាក់ អញ្ចឹងទឹកចេញមកខាងក្រៅ
គឺក្តៅអ៊ុនៗល្មមនឹងយើងងូត។

រូបភាពទី រូបភាពទី ៥ រូបភាពទី ៥ ក្រោយពេលដែលគាត់ចុចកុងតាក់ហើយ ទឹក
ទឹកក៏បានចេញពីក្បាល ចេញពីក្បាលផ្កាឈូក អញ្ចឹងយើងឃើញគាត់ងូតទឹក
ដោយទឹកនោះគឺទឹកក្តៅអ៊ុនៗ ដោយសារតែគាត់ចុចកុងតាក់
ដើម្បីឲ្យទឹកនោះចេញមកខាងក្រៅគឺក្តៅល្មម អញ្ចឹងយើងឃើញគាត់ គាត់

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

គាត់ងូតទឹកបណ្ដើរគាត់កក់សក់របស់គាត់បណ្ដើរ និង និងគាត់ដុសសាប៊ូនៅលើខ្លួនគាត់
និងគាត់ដុសសាប៊ូនៅលើខ្លួនគាត់បណ្ដើរ អញ្ចឹងគាត់ដុសសាប៊ូនៅលើខ្លួនរបស់គាត់មុន
បន្ទាប់មកគាត់កក់សក់របស់គាត់ គាត់កក់សក់របស់គាត់ គាត់កំពុងតែញីសក់របស់គាត់
ដើម្បីឲ្យសាប៊ូនោះជ្រាបចូលទៅសាច់ក្បាល ដើម្បីអាចកម្ចាត់មេរោគ
និងកុំឲ្យរមាស់នៅលើសាច់ក្បាល និងសាប៊ូដែលដុសខ្លួនគឺ សាប៊ូដែលដុសខ្លួន
អញ្ចឹងនៅពេលដែលយើងមាន[អារម្មណ៍] នៅពេលដែលខ្លួនរបស់យើងបែកញើស
ឬក៏មានធូលីដីក្រោយពេលដែលយើងជិះម៉ូតូចេញទៅខាងក្រៅ អញ្ចឹងពេលត្រលប់មកវិញ
ឬក៏ពេលត្រលប់មកវិញ យើងត្រូវដុសសាប៊ូនោះ ឬក៏ពេលខ្លះយើងដុសសាប៊ូដុសខ្លួននោះ
ដើម្បីឲ្យក្លិនខ្លួនរបស់យើងក្រអូប ដោយសារតែយើងបែកញើសពេញមួយថ្ងៃ
ដោយសារតែយើងបែកញើសពេញមួយថ្ងៃ ប៉ុន្តែពេលខ្លះក្រោយពេលដែលយើងក្រោកពីគេង
យើងចង់ យើងចង់ឲ្យ យើងចង់ឲ្យខ្លួនរបស់យើងក្រអូប ដូច្នេះយើង ដូច្នេះបុរសម្នាក់នោះគាត់បាន
គាត់បានដុស គាត់បានដុសសាប៊ូលើខ្លួនរបស់គាត់ និងកក់សក់របស់គាត់ ដោយគាត់ប្រើ
ដោយគាត់ប្រើទឹកក្ដៅអ៊ុនៗ ចេញពីម៉ាស៊ីន ម៉ាស៊ីនទឹកក្ដៅរបស់គាត់។

រូបភាពទី រូបភាពទី ៦ រូបភាពទី ៦ ក្រោយពេលដែលគាត់ងូតទឹក
និងជូតសម្អាតខ្លួនរបស់គាត់ស្ងួតហើយ គាត់ក៏ដើរត្រលប់មកបន្ទប់គេងរបស់គាត់វិញ
បន្ទាប់មកគាត់ក៏ប្ដូរខោអាវ អញ្ចឹងគាត់ដោះខោអាវគេងយប់ចេញ បន្ទាប់មកគាត់ក៏ពាក់[ឯកសណ្ឋាន]
គាត់ក៏ពាក់ឯកសណ្ឋានសាលាដើម្បីរៀបចំខ្លួនទៅសាលារៀន
យើងឃើញឯកសណ្ឋានសាលារបស់គាត់ យើងឃើញមាន យើងឃើញអាវរបស់គាត់ដូចជាអាវដៃខ្លី
អាវបើកកដៃខ្លី និងមានឡេវមួយជួរនៅខាងមុខ និងគាត់ស្លៀកខោពណ៌សជើងវែង
គាត់ស្លៀកខោពណ៌សជើងវែង អញ្ចឹងយើងឃើញគាត់កំពុងតែពាក់អាវ ពាក់អាវនិងកំពុងតែបិទឡេវ
ដោយសារតែអាវគាត់គឺមានឡេវមួយជួរនៅខាងមុខ អញ្ចឹងគាត់ គាត់ពាក់អាវ
គាត់ដោះអាវគេងយប់ចេញ អញ្ចឹងគាត់ពាក់អាវឯកសណ្ឋានសិស្សសាលា និងគាត់កំពុងតែ
គាត់កំពុងតែ គាត់កំពុងតែបិទឡេវ អញ្ចឹងគាត់បិទឡេវបណ្ដើរគាត់ក្រឡេកមើលទៅម៉ោងបណ្ដើរ
ដោយសារតែគាត់មិនចង់ឲ្យហួសម៉ោងរៀន
បន្ទាប់មកទៀតដោយសារតែអាកាសធាតុនៅខាងក្រៅត្រជាក់
គាត់ក៏បានទាញយកអាវដៃវែងមួយទៀតដែលជាអាវរងា ដើម្បីពាក់ខាងក្រៅ ដើម្បីពាក់ខាងក្រៅ
ពីព្រោះឯកសណ្ឋានសាលាគាត់គឺ បើទោះបីជា បើទោះបីជាខោជើងវែង ប៉ុន្តែអាវរបស់គាត់គឺអាវដៃខ្លី
ដូច្នេះប្រសិនបើគាត់ជិះម៉ូតូចេញទៅខាងក្រៅ អញ្ចឹងអាកាសធាតុនៅខាងក្រៅត្រជាក់ផង
ដូច្នេះអាចធ្វើឲ្យគាត់ អាចធ្វើឲ្យគាត់រងា អាចធ្វើឲ្យគាត់រងាបាន អញ្ចឹងគាត់ត្រូវពាក់អាវ
គាត់ត្រូវពាក់អាវមួយទៀត អាវដៃវែង ដែលយើងហៅថាអាវរងានោះនៅខាងក្រៅមួយជាន់ទៀត

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

អញ្ចឹងយើងឃើញគាត់ស៊កដៃបានម្ខាងហើយ បន្ទាប់មកគាត់ស៊កដៃម្ខាងទៀត
អញ្ចឹងគាត់ស៊កអាវចូលខ្លួនបណ្ដើរគាត់មើលម៉ោងបណ្ដើរ។ បន្ទាប់មកទៀត
ក្រោយពេលដែលគាត់ពាក់អាវរងាស៊កចូលខ្លួនរបស់គាត់រួចរាល់ហើយ
គាត់ក៏បានទាញយកមួកសុវត្ថិភាពពាក់នៅលើក្បាលរបស់គាត់
ដើម្បីការពារសុវត្ថិភាពនៅពេលដែលជិះម៉ូតូ
អញ្ចឹងជាទូទៅអ្នកដែលជិះឡានគឺគាត់ពាក់ខ្សែក្រវ៉ាត់សុវត្ថិភាព ប៉ុន្តែអ្នកដែលជិះម៉ូតូយើងត្រូវពាក់
យើងត្រូវពាក់មួកការពារសុវត្ថិភាព ដើម្បីការពារក្បាលរបស់យើង ប្រសិនបើយើងមានការដួល
ឬក៏ប៉ះទង្គិច ត្រូវនឹងក្បាលមួកការពារអាចជួយការពារក្បាលរបស់យើងបាន
អញ្ចឹងយើងឃើញគាត់បានទាញមួកការពារមកពាក់នៅលើក្បាលរបស់គាត់។

បន្ទាប់មកទៀតរូបភាពទី ៧ រូបភាពទី ៧ ក្រោយពេលដែលគាត់រៀបចំខ្លួនរួចរាល់ហើយ
និងពាក់មួកសុវត្ថិភាពរួចរាល់ហើយ គាត់ក៏បានឡើងម៉ូតូ និងជិះម៉ូតូទៅសាលារៀន។
យើងឃើញម៉ូតូរបស់គាត់ យើងឃើញ យើងឃើញម៉ូតូរបស់គាត់ យើងឃើញមានកង់ពីរ
កង់ខាងមុខមួយ កង់ខាងក្រោយមួយ។ នៅខាងមុខម៉ូតូយើងឃើញមានចង្កៀង ឬក៏ភ្លើង
ឬក៏អំពូលភ្លើងម៉ូតូ ប្រើសម្រាប់បំភ្លឺផ្លូវនៅពេលយប់ ឬក៏នៅពេលភ្លៀង
ឬក៏នៅពេលដែលមានមេឃងងឹត និងយើងឃើញមានកញ្ចក់ដាក់អម ដាក់សងខាង
កញ្ចក់គឺយើងប្រើសម្រាប់ងាយស្រួលមើលទៅខាងក្រោយ ប្រសិនបើយើងអត់ពាក់មួកសុវត្ថិភាព
និងម៉ូតូរបស់យើងអត់ដាក់កញ្ចក់ទេ ពេលខ្លះប៉ូលិសនឹងផាក
ពេលខ្លះប៉ូលិសនឹងផាកលុយរបស់យើង ដោយសារតែយើងមិនបានពាក់មួកសុវត្ថិភាព
និងដាក់កញ្ចក់សម្រាប់មើលក្រោយ ឬក៏មើលឆ្វេងស្ដាំ អញ្ចឹងយើងឃើញម៉ូតូគាត់លឿន
អញ្ចឹងគាត់ជិះម៉ូតូយ៉ាងលឿនទៅសាលារៀន។

រូបភាពទី រូបភាពទី ៨ រូបភាពទី ៨ រូបភាពទី ៨ គាត់ក៏ គាត់ក៏ជិះម៉ូតូមកដល់សាលា
ប៉ុន្តែគាត់ត្រូវចុះពីលើម៉ូតូបណ្ដើរម៉ូតូចូលទៅក្នុងកន្លែងផ្ញើម៉ូតូ អញ្ចឹងប្រហែលជាសាលាមួយចំនួន
គាត់អត់អនុញ្ញាតឲ្យយើងជិះម៉ូតូចូលទៅខាងក្នុងទេ។ អញ្ចឹងយើងត្រូវបណ្ដើរម៉ូតូចូលទៅខាងក្នុង
ដោយយើងឃើញនៅខាងក្នុងបរិវេណសាលានោះមានម៉ូតូជាច្រើន ដែលឈប់ចតនៅទីនោះ
ដែលម៉ូតូទាំងអស់នោះជាម៉ូតូរបស់សិស្សសាលាផ្សេងៗទៀត
ដែលគាត់ប្រើម៉ូតូនេះជាមធ្យោបាយធ្វើដំណើរពីផ្ទះរបស់គាត់មកសាលារៀន
អញ្ចឹងយើងឃើញនៅសាលាខ្លះកន្លែងផ្ញើម៉ូតូគឺយក ២០០ ឬក៏ ៥០០។ ៥០០
អញ្ចឹងគាត់កិបសំបុត្រឲ្យយើង អញ្ចឹងគាត់មើលថែម៉ូតូរបស់យើងរហូតដល់យើងចប់ ចប់ថ្នាក់រៀន
យើងអាចមកយកម៉ូតូបានដោយគ្រាន់តែបង្ហាញសំបុត្រម៉ូតូទៅគាត់ និង និងឲ្យលុយទៅគាត់ ២០០

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ឬក៏ ៥០០ អញ្ចឹងគាត់នឹងអនុញ្ញាតឲ្យយើងយកម៉ូតូនោះ អញ្ចឹងកន្លែងខ្លះគឺយក ២០០ ឬក៏ ៣០០ កន្លែងខ្លះយកថ្លៃផ្ញើម៉ូតូ ៥០០។ ប៉ុន្តែកន្លែងខ្លះគឺយកថ្លៃផ្ញើម៉ូតូ ១០០០ អញ្ចឹងវាតាមកន្លែង តាមកន្លែង ប៉ុន្តែជា ប៉ុន្តែនៅក្នុងសាលាដោយសារតែពួកគាត់គឺជាសិស្ស អញ្ចឹងពួកគាត់អត់ទាន់មានការងារធ្វើនៅឡើយទេ។ គាត់ចាយលុយរបស់ឪពុកម្ដាយរបស់គាត់ របស់ពួកគាត់ អញ្ចឹងជាទូទៅការផ្ញើម៉ូតូនៅសាលាគឺអត់ថ្លៃទេ គឺត្រឹមតែ ២០០ ៣០០ ឬក៏យ៉ាងច្រើន ៥០០ តែប៉ុណ្ណោះ អញ្ចឹងយើងឃើញគាត់មកដល់សាលា គាត់ចុះពីលើម៉ូតូ និងគាត់ចុះពីលើម៉ូតូ យើងឃើញគាត់ស្ពាយកាបូប កាបូប ដែលនៅក្នុងកាបូបនោះគឺមានសម្ភារៈសម្រាប់សិក្សា មានដូចជាសៀវភៅ មានសៀវភៅ ប៊ិច ឬក៏ខ្មៅដៃ អញ្ចឹងយើងឃើញ[របស់] យើងឃើញ សម្ភារៈសម្រាប់សិក្សាគឺគាត់ដាក់នៅក្នុងកាបូបស្ពាយខាងក្រោយរបស់គាត់ អញ្ចឹងនៅពេលដែលគាត់មកដល់សាលា គាត់មកដល់សាលា គាត់ក៏បណ្ដើរម៉ូតូចូលទៅសាលាដើម្បី ដើម្បីឈប់ចតម៉ូតូនោះនៅកន្លែងផ្ញើម៉ូតូ។

បន្ទាប់មកទៀតរូបភាពទី ៩ រូបភាពទី ៩
ក្រោយពេលដែលគាត់ចតម៉ូតូនោះឈប់នៅក្នុងបរិវេណសាលារួចហើយ គាត់ក៏បានបើកកែបម៉ូតូ គាត់ក៏បើកកែបម៉ូតូដែលនៅខាងក្នុងនោះគឺជាកន្លែងសម្រាប់ចាក់សាំង និងនៅក្នុងនោះគឺមាន គឺមានថតមួយសម្រាប់ដាក់អីវ៉ាន់ សម្រាប់ដាក់អីវ៉ាន់ចូលទៅក្នុងនោះ អញ្ចឹងយើងអាចបើកកែបម៉ូតូ និងដាក់អីវ៉ាន់ និងដាក់អីវ៉ាន់ចូលទៅខាងក្នុងកែបម៉ូតូនោះ អញ្ចឹងដោយសារតែ ដោយសារតែគាត់មកដល់សាលា អញ្ចឹងគាត់អត់អាចពាក់មួកការពារសុវត្ថិភាព ឬក៏អាវរងាចូលទៅក្នុងសាលាបានទេ អញ្ចឹងគាត់ត្រូវបើកកែបម៉ូតូនោះដើម្បីដាក់របស់ទាំងអស់នោះចូលទៅខាងក្នុង។

បន្ទាប់មកទៀតរូបភាពទី ១០ រូបភាពទី ១០ ក្រោយពេលដែលគាត់បើកកែបម៉ូតូនោះរួចរាល់ហើយ គាត់ក៏បានដោះអាវរងាចេញពីខ្លួនរបស់គាត់ បន្ទាប់មកគាត់ក៏បានដោះមួកការពារសុវត្ថិភាពចេញពីលើក្បាលរបស់គាត់ និងគាត់ដាក់មួកការពារសុវត្ថិភាពនិងអាវរងាចូលទៅក្នុង ចូលទៅក្នុងកែបម៉ូតូរបស់គាត់ ដែលយើងឃើញនៅពេលដែលគាត់បើកកែបម៉ូតូ យើងឃើញមានឃ្លុបមួយនៅខាង យើងឃើញមានឃ្លុបមួយ ដែលឃ្លុបម៉ូតូនោះគឺយើងប្រើ គឺយើងអាចដាក់ យើងអាចដាក់អីវ៉ាន់ យើងអាចដាក់អីវ៉ាន់ ឬក៏នៅ នៅខាងក្នុងនោះគឺជាកន្លែងសម្រាប់ចាក់សាំងផងដែរ។ និងមានប្រឡោះមួយ យើងអាចដាក់អីវ៉ាន់នៅខាងក្នុងនោះបានយ៉ាងងាយស្រួល ពីព្រោះប្រសិនបើយើងដាក់មួកនៅខាងក្រៅ ពេលខ្លះ ពេលខ្លះអាចបាត់ដោយសារតែមានអ្នកចូលមកខាងក្នុងសាលា

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

និងលួចយកម្ហូកនៅលើម៉ូតូរបស់យើង អញ្ចឹងយើងឃើញគាត់ប្រយ័ត្ន
អញ្ចឹងយើងឃើញគាត់មានការប្រុងប្រយ័ត្ន
គាត់យកម្ហូកនិងអាវរងានោះដាក់ចូលទៅក្នុងម៉ូតូរបស់គាត់ ឬក៏ថតម៉ូតូរបស់គាត់ ឬក៏
ឬក៏ឃ្លុបម៉ូតូរបស់គាត់។

បន្ទាប់មកទៀតរូបភាពទី ១១ ក្រោយពេលដែលគាត់ដាក់ម្ហូកការពារសុវត្ថិភាព
ឬក៏អាវរងារួចរាល់ហើយ គាត់ក៏បានបិទកែបម៉ូតូរបស់គាត់វិញ។
អញ្ចឹងនៅពេលដែលគាត់បិទកែបម៉ូតូ អត់មានអ្នកណាអាច
អត់មានអ្នកណាអាចបើកកែបម៉ូតូនោះបានទេ ដោយសារតែកែបម៉ូតូនោះគឺមានចាក់សោ
ដូច្នេះមិនអាច មិនអាចបើកកែបម៉ូតូនោះលួចយកម្ហូកឬក៏អាវរងានោះបានទេ។

រូបភាពទី ១២ យើងឃើញ យើងឃើញមាននាឡិកាពីរចង្អុលទៅម៉ោង ទី ១ គឺចង្អុលទៅម៉ោង ៨
ព្រឹក ៨ ព្រឹក អញ្ចឹងជាទូទៅអាកាសធាតុត្រជាក់គឺនៅពេលព្រឹក និងនៅពេលល្ងាច
គឺអាកាសធាតុត្រជាក់ ប៉ុន្តែយើងឃើញម៉ោងទី ២ គឺចង្អុលទៅកាន់ម៉ោង ១ គឺចង្អុលទៅកាន់ម៉ោងជិត
១ ខ្វះ ខ្វះ[៤០] ខ្វះ ៤០ នាទីទៀតគឺម៉ោង ១។ អញ្ចឹងអាកាសធាតុចាប់ផ្តើមក្តៅ
ជាទូទៅអាកាសធាតុត្រជាក់ភាគច្រើនគឺនៅពេលព្រឹកព្រលឹម ព្រឹកព្រលឹម និងនៅពេលល្ងាច
អញ្ចឹងចាប់ផ្តើមមានខ្យល់ និងអត់មានពន្លឺថ្ងៃ។ ប៉ុន្តែចាប់ផ្តើមពីម៉ោង ១២ ឬក៏ម៉ោង ១
គឺអាកាសធាតុចាប់ផ្តើមក្តៅបន្តិច អញ្ចឹងយើងឃើញ[រូប] យើងឃើញនាឡិកាទី ១
គឺចង្អុលទៅលើអាកាសធាតុនៅពេលព្រឹកព្រលឹមគឺវារៀងត្រជាក់បន្តិច។ នាឡិកាទី ២
គឺចង្អុលទៅកាន់ចំណុចជិតម៉ោង ចង្អុលទៅកាន់លេខជិតម៉ោង ១ ដូច្នេះអាកាសធាតុប្តូរទៅរាង
រាងក្តៅបន្តិច។

បន្ទាប់មកទៀតរូបភាពទី ១៣ រូបភាពទី [១]៣ យើងឃើញនៅក្នុងសាលារៀនយើងឃើញ
យើងឃើញសាលារៀន
យើងឃើញមានកូនសិស្សជាច្រើនកំពុងដើរចូលទៅក្នុងថ្នាក់រៀនរបស់ពួកគាត់ របស់ពួក
របស់ពួកគាត់ យើងឃើញ យើង ដោយសារតែពួកគាត់រៀននៅវេនថ្ងៃ យើងឃើញព្រះអាទិត្យរះ
និងមានកម្តៅក្តៅ ព្រះអាទិត្យរះ និងមានកម្តៅក្តៅ និងមាន និងមានដុំពពកផងដែរ។
អញ្ចឹងយើងឃើញសាលារៀនរបស់គាត់មានដំបូលពណ៌ទឹកក្រូច និងជញ្ជាំងសាលារៀនគឺលាបពណ៌
ភាគច្រើនគឺលាបពណ៌លឿង ឬក៏លាបពណ៌ ឬ ឬក៏លាបពណ៌ទឹកក្រូចតិចៗ ទឹកក្រូចតិចៗ។
អញ្ចឹងយើងឃើញសិស្សសាលាទាំងអស់កំពុងតែរៀបចំ កំពុងតែរៀបចំខ្លួនចូលរៀន
រៀបចំខ្លួនចូលទៅក្នុងថ្នាក់ ឬក៏ដើម្បីចូលរៀន

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

យើងឃើញនៅខាងមុខសាលារបស់គាត់មានទង់ជាតិមួយ ដែលទង់ជាតិនោះគឺយើងប្រើសម្រាប់
គឺយើងប្រើសម្រាប់ច្រៀងចម្រៀងជាតិនៅពេលព្រឹកនិងនៅពេលល្ងាច។
អញ្ចឹងមានន័យថានៅពេលព្រឹកគឺយើងច្រៀងចម្រៀងបទគោរពទង់ជាតិ
និងបង្ហូតទង់ជាតិឡើងទៅលើ និងនៅពេលដែលត្រូវខ្យល់ទង់ជាតិនោះបក់រវិច។
ប៉ុន្តែនៅពេលល្ងាចម៉ោង ៥ នៅពេលដែលសិស្សសាលាទាំងអស់ចេញពី ចេញពីសាលារៀន
អញ្ចឹងយើងត្រូវជួបជុំគ្នាតម្រង់ជួរគោរពទង់ជាតិម្តងទៀត ដើម្បីបង្ហូតទង់ជាតិនោះចុះមកខាងក្រោម
ដើម្បីយកទង់ជាតិនោះទៅរក្សាទុកនៅក្នុងបន្ទប់។ អញ្ចឹងនៅពេលព្រឹកគឺយើងបង្ហូតឡើងទៅខាងលើ
នៅពេលល្ងាចគឺយើងបង្ហូតទង់ជាតិចុះមកខាងក្រោម និងមានច្រៀងចម្រៀងបទទង់ជាតិផងដែរ។

រូបភាពទី ១៤ រូបភាពទី ១៤ ដោយសារតែអាកាសធាតុក្តៅនៅពេលអំឡុងម៉ោង ១២ ឬក៏ម៉ោង ១
ព្រះអាទិត្យចាប់ផ្តើមរះ និងមានដុំពពកយ៉ាងក្រាស់ អញ្ចឹងចាប់ផ្តើមអាកាសធាតុចាប់ផ្តើមក្តៅ
អញ្ចឹងយើងឃើញបុរសម្នាក់នោះគាត់ដើរ គាត់ដើរបណ្តើរ យើងឃើញមានញើសហូរមក
យើងឃើញមានញើសហូរធ្លាក់មកបណ្តើរ។ អញ្ចឹង
អញ្ចឹងយើងឃើញនៅពេលព្រឹកគឺអាកាសធាតុត្រជាក់គាត់ពាក់អាវរងា
ប៉ុន្តែនៅពេលដែលមានកម្តៅ[ថ្ងៃ] ប៉ុន្តែនៅពេលដែលបើកថ្ងៃ ឬ នៅពេលដែលបើកថ្ងៃ
មានព្រះអាទិត្យនិងមានដុំពពកក្រាស់ៗ អញ្ចឹងចាប់ផ្តើមក្តៅធ្វើឲ្យគាត់បែកញើស។ អញ្ចឹងគាត់ដើរ
គាត់ដើរបណ្តើរញើសហូរបណ្តើរ អញ្ចឹងយើងឃើញគាត់ពាក់ឯកសណ្ឋានសិស្ស
ឯកសណ្ឋានរបស់គាត់នឹងទទឹកដោយសារតែញើសហូរធ្លាក់
ដោយសារតែញើសរបស់គាត់ហូរធ្លាក់ចុះមកខាងក្រោម។ និងគាត់មានស្ពាយកាបូបនៅខាងក្រោយ
ដែលកាបូបរបស់គាត់គឺដាក់សម្ភារៈសម្រាប់សិក្សា ឬក៏កាបូបលុយនៅខាងក្នុងនោះ។
អញ្ចឹងយើងឃើញគាត់មើលទៅដូចជាក្តៅស្អុះ ដោយសារតែមានញើសហូរធ្លាក់
ដោយសារតែមានញើសហូរមកយ៉ាងខ្លាំង និងគាត់ដើរនៅក្រោមពន្លឺព្រះអាទិត្យផងដែរ។

រូបភាពទី ១៥ រូបភាពទី ១៥ យើងឃើញ យើងឃើញនាឡិកាចង្អុលទៅកាន់ម៉ោង ៦ ល្ងាច
អញ្ចឹងម៉ោង ៦ ល្ងាចគឺគាត់ត្រលប់ គឺគាត់ចេញពីសាលា គឺគាត់ចេញពីរៀន គឺគាត់ចេញពីរៀន
អាចត្រលប់មកផ្ទះវិញបាន អញ្ចឹងនៅម៉ោង ៦ ល្ងាចព្រះអាទិត្យលិច យើងឃើញព្រះអាទិត្យលិច
អាកាសធាតុចាប់ផ្តើមត្រជាក់ម្តងទៀត អាកាសធាតុចាប់ផ្តើមត្រជាក់ឬក៏រងាម្តងទៀត
ដោយមានខ្យល់បក់ និង ដោយមានខ្យល់បក់ និងនៅពេលដែលយើង
និងនៅពេលដែលព្រះអាទិត្យលិច អញ្ចឹងនៅពេលដែលព្រះអាទិត្យលិចនិងមានខ្យល់ផងនោះ
អញ្ចឹងអាកាសធាតុចាប់ផ្តើមត្រជាក់ម្តងទៀត។ អញ្ចឹងយើងឃើញម៉ោង
អញ្ចឹងជាទូទៅអាកាសធាតុត្រជាក់គឺចាប់ផ្តើមពីម៉ោង ពីព្រឹកព្រលឹម ពីព្រឹកព្រលឹម និងពេលល្ងាច

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

និងពេលល្ងាច អាកាសធាតុចាប់ផ្ដើមត្រជាក់ម្ដងទៀត។ អញ្ចឹងនៅម៉ោងជិត ៦ យើងក្រឡេកមើលទៅខាងក្រៅបង្អួច យើងឃើញមានផ្ទះមួយគឺនៅក្បែរភ្នំ អញ្ចឹងយើងឃើញព្រះអាទិត្យគឺលិច គឺលិច និងមានដុំពពកផងដែរ។

រូបភាពទី រូបភាពចុងក្រោយ រូបភាពទី ១៦ រូបភាពទី ១៦ ដោយសារតែ ដោយសារតែម៉ោង ៦ ដោយសារតែម៉ោង ៦ ហើយ ដូច្នេះសាលាគឺ គឺបញ្ចប់ គឺសាលាគឺបញ្ចប់។ សិស្សដែលរៀននៅក្នុងសាលាទាំងអស់គឺពួកគាត់អាចត្រលប់មកផ្ទះវិញបាន។ អញ្ចឹងបុរសម្នាក់នោះគាត់ក៏បាន បុរសម្នាក់នោះគាត់ក៏បានជិះម៉ូតូត្រលប់មកផ្ទះរបស់គាត់វិញ យើងឃើញគាត់ជិះម៉ូតូរបស់គាត់ យើងឃើញគាត់ជិះម៉ូតូរបស់គាត់យ៉ាងលឿន និងគាត់ពាក់អាវ និងគាត់ពាក់អាវរងា អញ្ចឹងគាត់យកមួកការពារនិងអាវរងាចេញពី ចេញពីកែបម៉ូតូ ចេញពីកែបម៉ូតូខាងក្នុង។ អញ្ចឹងគាត់យកមួកនិងអាវរងានោះយកមកពាក់ អញ្ចឹងគាត់ពាក់អាវរងាដោយសារតែពេលល្ងាចអាកាសធាតុចាប់ផ្ដើមត្រជាក់ម្ដងទៀត និងគាត់ពាក់មួកការពារសុវត្ថិភាពដោយសារតែគាត់ជិះម៉ូតូត្រលប់ទៅផ្ទះវិញ។ ដូច្នេះគាត់ត្រូវពាក់មួកសុវត្ថិភាពគ្រប់ពេលនៅពេលដែលគាត់បើកបរ និងយើងឃើញគាត់ស្ពាយកាបូបនៅខាងក្រោយខ្នងរបស់គាត់ អញ្ចឹងយើងឃើញគាត់ យើងឃើញគាត់ពាក់អាវរងាស្លៀកខោជើងវែងជាមួយនឹងស្បែកជើងប៉ាតា និងមួកការពារ និងមាន និងមានកាបូបស្ពាយនៅខាងក្រោយ និងមានកាបូបស្ពាយនៅខាងក្រោយផងដែរ។ អញ្ចឹងគាត់កំពុងតែជិះម៉ូតូត្រលប់មកផ្ទះរបស់គាត់វិញក្រោយពេលដែលគាត់ ក្រោយពេលដែលគាត់ នៅពេលដែលគាត់ចេញពីសាលា ឬក៏នៅពេលដែលគាត់រៀនចប់ពីសាលា។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.